# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ៤២៦ PC. អក

## សេចក្ដីជូនដំណឹង

អគ្គិសនីកម្ពុជាសូមជូនដំណឹងលើកទី២ ដល់បណ្ដា ក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់អោយដេញថ្លៃប្រកួតប្រជែងជាសាធារណៈ និង ពិគ្រោះថ្លៃប្រកួតប្រជែងជាសាធារណៈ ដើម្បីផ្គត់ផ្គង់សម្ភារ និងឈ្នួលពលកម្ម ដូចខាងក្រោម៖

| ល.រ | បរិយាយ | កាលបរិច្ឆេទ លក់ និងទទួល ឯកសារ | កាលបរិច្ឆេទ ឈប់ទទួល ឯកសារ | កាលបរិច្ឆេទ បើកឯកសារ |
|---|---|---|---|---|
| I | ឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈ | | | |
| 1 | ការផ្គត់ផ្គង់ Thermal Image Camera ចំនួន ០៦មុខ (កញ្ចប់លេខ ១៤) សម្រាប់ប្រើប្រាស់តាមបណ្ដាអនុស្ថានីយអគ្គិសនី ជូន នាយកដ្ឋានបញ្ជូនអគ្គិសនី ។ Code: 20TBLS143 | 06-01-2021 | 09-02-2021 ម៉ោង 14:00 | 09-02-2021 ម៉ោង 15:20 |
| 2 | ការងារផ្គត់ផ្គង់សម្ភារ និងឈ្នួលពលកម្ម ពង្រីកបណ្ដាញតង់ស្យុងមធ្យម 22KV ឆ្លងទន្លេមេគង្គ ទៅភូមិកោះព្រះ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ។ Code: 21DBLSL08 | 21-01-2021 | 23-02-2021 ម៉ោង 14:00 | 23-02-2021 ម៉ោង 15:00 |
| II | ឯកសារពិគ្រោះថ្លៃ | | | |
| 8 | ការផ្គត់ផ្គង់ Spare Part of Bushing Transformer 22KV និង 15KV សម្រាប់ GS3 ចំនួន ០២មុខ (កញ្ចប់លេខ ២៩) ផែនការឆ្នាំ២០២០ ជូន អង្គភាពបណ្ដាញបញ្ជូន នៃនាយកដ្ឋានបញ្ជូនអគ្គិសនី ។ Code: 20TQS013 | 26-01-2021 | 09-02-2021 ម៉ោង 14:00 | 09-02-2021 ម៉ោង 15:15 |

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋាន ៖ អាគារលេខ២, ផ្លូវព្រះយុគន្ធរ, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានី ភ្នំពេញ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ៖ 023 67 66 007 និង Website : www.edc.com.kh) ។

ក្រុមហ៊ុន/សហគ្រាស ដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់មកបន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលមានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលមានឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃ បានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃ ។

ថ្ងៃពុធ ១៤កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២១

ត- ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហង់_ធូច

ចម្លងជូន៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ